# នេះសាត្រាច្បាប់ក្មេង

១. នេះគឺច្បាប់ក្មេង លោកគិតតាក់តែង ចង់ជាសត្រា<br>
ឱ្យអស់គ្រប់ខ្លួន ថែថ្នូនឧស្សាហ៍ តាមច្បាប់នេះណា<br>
កុំបីមើលងាយ។

២. ហៃអស់ក្មេងផង យកកាណ៌ទាំងសង ចូរស្ដាប់អភិប្រាយ<br>
គ្រូលោករកហៅ កុំទៅលេងឆ្ងាយ ធ្វេសធ្វើវាយមាយ<br>
ហាក់ពុំកោតគ្រូ។

៣. ទោះលោកវាយដំ ឱ្យប្រឹងខិតខំ ឯងកុំមួទូ<br>
សង្វាតសូត្ររៀន របៀននឹងគ្រូ នមោកខ<br>
តាមដោយប្រាជ្ញា។

៤. លោកមិនបន្ទោស បើខ្ជិលប្រអូស នោះឯងលោកថា<br>
ក្រែងត្រូវរំពាត់ លំបាកអាត្មា ត្បិតពុំឧស្សាហ៍<br>
គំនិតខ្លួនឯង។

៥. បើត្រូវលោកវាយ ឯងទៅប្រាប់ម្ដាយ ថាលោកពុំឈ្វេង<br>
លោកគ្រូនេះកាច កំណាចនឹងក្មេង លោកវាយតែឯង<br>
ខ្ញុំគ្មានខុសទេ។

៦. បពិត្រអ្នកម៉ែ កូនរៀនសព្វថ្ងៃ មិនឱ្យទំនេ<br>
ម្ដេចឡើយលោកគ្រូ លោកវាយលោកជេរ ស្អប់ខ្ញុំជាងគេ<br>
លើសអស់សិស្សផង។

៧. រីឯមាតា ស្ដាប់កូនចរចា ដំណើរដើមទង<br>
កើតខឹងក្រេវក្រោធ ពិរោធមានហ្មង នឹងកើតទោសច្ពង<br>
ដោយសារខ្លួនខ្លៅ។

៨. ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មិនដែលដូច្នោះ

ពុំយកពាក្យកូន    សព្វសូន្យអសុរស    ដឹងបុណ្យសក្តិយស
    ទូន្មានប្រដៅ។

៩. កូនខ្មើយមាត្រា    ច្បាប់រៀនធម៌អាថ៌    លោកតែងពោលដេរ
មិនឱ្យអាក្រក់    មានមុខហ្មងសៅ    កុំបាយោយៅ
    ទាស់ពុទ្ធដិកា។

១០. កូនកុំអល់អែក    ធ្វើចេះជាងពេក    លើសលោកវិញណា
កុំបាទូលទាស់    ក្នុងពុទ្ធដិកា    មិនដាក់សិរិសា
    ស្តាប់យកពាក្យនេះ។

១១. បារៀនឱ្យចេះ    គ្រាន់ពឹងចំណេះ    លើកមុខសន្តាន
លើកមុខអ្នកម្តាយ    ឪពុកបាបាន    ច្បាប់គ្រូទូន្មាន
    មិនឱ្យអាក្រក់។

១២. ទោះគ្រូប្រដៅ    ដេរពោលរកហៅ    កុំបាតក់មក់
ធ្វើចិត្តឱ្យត្រង់    កុំពោលកុហក់    ប្រែខ្នងសម្ងក់
    ក្រញ៉ើងតវិញ។

១៣. គ្រូលោកទូន្មាន    ទីទៃគ្រប់ប្រាណ    អស់សិស្សនោះមិញ
លោកមិនមានស្អប់    មិនមានស្រឡាញ់    លោកជួយបំពេញ
    ថ្កើងកេរ្តិ៍ឈ្មោះម្តាយ។

១៤. ..................    ថ្កើងកេរ្តិ៍ឪពុក    សន្តានជិតឆ្ងាយ
ត្បិតបានបាឯង    ជាអ្នកប្រាជ្ញប្រាយ    ញាតិផងទាំងឡាយ
    ពឹងពាក់អាស្រ័យ។

១៥. បើបាធ្វើកាច    គ្រូឯងមិនខ្លាច    លោកដេរពោលវាយ
កុំឯងប្រកែក    ជជែកតថ្លៃ    ព្រះគុណថ្លាថ្លៃ
    ប្រដៅឱ្យផ្លូវ។

១៦. ចាប់ពីម្តាយផ្តាំ    ដាក់ទុកលាំទាំ    និងលោកជាគ្រូ
កុំបាឯងឱង    ធ្វើកាចមូទូ    កោតខ្លាចលោកគ្រូ

| | | |
|---|---|---|
| | ដូចពាក្យម្ដាយថា។ | |
| ១៧. ទោះលោកគ្រូចាន់ | អង្គុយខ្នាប់ខ្នាន់ | គង់គល់ត្រៀបត្រា |
| កុំដើរលេងឆ្ងាយ | រាយមាយឡើយណា | មើលហិបចាកស្លា |
| | ដងទឹកផ្គត់ផ្គង់។ | |
| ១៨. ពេលគ្រូចាន់ព្រឹក | ស្រវៀបរអឹក | វេលាថ្ងៃត្រង់ |
| រៀបតាមលំដាប់ | លោកគ្រូព្រះអង្គ | បំរើអស់សង្ឃ |
| | បរិស័ទក្នុងវត្ត។ | |
| ១៩. ចូរបាឯងអាច | លំទោនកោតខ្លាច | គោរពប្រណិបត្តិ |
| អស់លោកគ្រប់អង្គ | គង់ជាបរិស័ទ | ប៉ុន្មានក្នុងវត្ត |
| | កោតខ្លាចទាំងអស់។ | |
| ២០. បាខ្លាចតែគ្រូ | អស់លោកមូទូ | ស្រដីទ្រគោះ |
| នឹងមានដំនៀល | ដៀលដល់ម្ដាយនោះ | និងអាស្រូវឈ្មោះ |
| | ពីលោកទាំងឡាយ។ | |
| ២១.ថាកូនអ្នកណា | ប្រដៅដេរថា | ឱ្យបង់ប្រាជ្ញប្រាយ |
| ប្រដៅថាទៅ | ប្រែជាមាក់ងាយ | កេរ្តិ៍ឈ្មោះដល់ម្ដាយ |
| | កូន្នើយពុំជា។ | |
| ២២. បើបាធ្វើច្នោះ | និងកើតអាប់យស | កេរ្តិ៍គេនិន្ទា |
| មិនចេះខ្លាចក្រែង | ចាស់ទុំរាល់គ្នា | ក្នុងច្បាប់លោកថា |
| | ហៅប្រុសអន្ធពាល។ | |
| ២៣. ធម្មតាជាប្រុស | មិនឱ្យអាប់យស | ត្រង់ច្បាប់ធូន់ស្រាល |
| ឱ្យដឹងខុសគាប់ | កុំត្រាប់មនុស្សពាល | វានាំត្រអាល |
| | ខូចខ្លួនអាសារ។ | |
| ២៤.បាខំចេញបួស | បំពេញព្រះផ្នួស | ក្នុងពុទ្ធសាសនា |
| នឹងនាំយកម្ដាយ | ឪពុកនៃបា | ទូវញាតិកា |
| | ប្រាំពិលសន្តាន។ | |

២៥.បាខំប្រឹងរៀន ទាំងអស់របៀន ចំណេះបាបាន
អក្សរសត្រា ធម៌អាចិប៉ុន្មាន ទេសនាទូន្មាន
ប្រោសម្តាយនោះផង។
២៦.ខ្លួនម្តាយជាស្រី ពឹងបុត្រពិសី ឱ្យអ្នកចម្លង
ម្តាយរួចពីទុក្ខ សមុទ្រធ្លះធ្លង បានរួចរំលង
ដល់ត្រើយនិព្វាន។
២៧. មានតែអ្នកផ្នួស ត្បិតបាបានបួស បំពេញសិលទាន
ក្នុងពុទ្ធសាសនា ចម្លងម្តាយបាន ផលអ្នកជាស្ពាន
រួចដល់ត្រើយនាយ។
២៨. ម្តាយសង្ឃឹមមបា ជាបុត្រសង្ឃារ ប្រសើរពន្រាយ
ត្បិតបានបាឯង ជាអ្នកទៅឆ្ងាយ ហៅមហាទូលាយ
លើសលែងលោកីយ។
២៩. កូន្ទើយលោកថា បួសក្នុងសាសនា មិនឱ្យអប្រិយ៍
ប្រុងរៀនអក្សរ ធម៌អាចិបាលី តាមព្រះជិនស្រី
ទេសនាទូន្មាន។
៣០. បើបួសជាសង្ឃ រៀនធម៌ឱ្យប្រុង គ្រាន់សូត្រនិងគេ
កុំឱ្យអាប់មុខ រកធម៌សូត្រគ្មាន (ឱ) បាសកប៉ុន្មាន
ក្រែងគេនិន្ទា។
៣១. គេថាច្នេះច្នោះ ចំពោះត្រង់ណោះ ត្រង់នាមអាត្មា
មកបួសនិងគេ មិនចេះធម៌អាចិ សូត្រធម៌កុសលា
បាំងផ្ចិតទទេ។
៣២.ពិស្តារតិរោក គេសូត្រកោក។ ឯងធ្វើព្រងើយ
ត្រឡប់ត្រឡិន មិនប៉ិនដូចគេ បាំងផ្ចិតទទេ
បែកញើសគយរ ។
៣៣.បាអើយច្បាប់នេះ បើធ្វើដូច្នេះ ម្តាយមិនត្រេអរ

ក្បិតបាមកបួស    មិនសូវកុះក    ធម៌អាថ៌អក្សរ
បាមិនសូវស្ទាត់។
៣៤.ទៅរៀននឹងគ្រូ    បើលោកមួទូ    បាឯងបានចិត្ត
លុះដល់លោកវាយ    ថាមិនអាណិត    បណ្តោយតាមចិត្ត
ខូចខ្លួនមិនចេះ។
៣៥. ទោះគ្រូប្រដៅ    ដេរពោលរកហៅ    កុំឯងធ្វើក្រអេះ
ដល់ខ្លួនរៀនទៅ    ពុំសូវបានចេះ    អាប់ឱនចំណេះ
ខ្មាស់គេឬទេ។
៣៦. កាលលោកខិតខំ    ចង់ឱ្យបានធំ    មុខមាត់នឹងគេ
ក្បិតលើខ្លួនឯង    ពុំឈ្វេងរិះរេ    ព្រោះតែលោកដេរ
ខឹងនិងលោកវិញ។
៣៧.ហៃកូនពិសី    ច្បាប់នេះក្រក្រៃ    លោកជួយបំពេញ
ចង់ឱ្យមានឈ្មោះ    កេរ្តិ៍យសនោះមិញ    ឱ្យគេស្រឡាញ់
រាប់អានគ្រប់គ្នា។
៣៨.ម្តេចឡើយបាឯង    មិនកោតខ្លាចក្រែង    ខុសនិងមាត្រា
កោតគ្រូបាធ្យាយ    ស្វាធ្យាយឧស្សាហ៍    ខំរៀនធម៌អាថ៌
តាមគ្រូប្រដៅ។
៣៩. កោតថាមិនចេះ    វាគ្មានចំណេះ    បន្ទោសថាខ្លៅ
មិនដោយទូន្មាន    គ្រូលោកប្រដៅ    ខ្លួនឯងចោតខ្លៅ
ពុំស្តាប់ពុទ្ធដិកា។
៤០.បាអើយក្រវើន    ថែទាំដាស់តឿន    ទាំងអស់គ្នីគ្នា
ម្តាយផ្តែផ្តាំបុត្រ    បរិសុទ្ធពុំងា    រៀងរួចដល់មហា
បរមនិព្វានហោង។

ចារចប់នៅព្រឹកម៉ោង៧ ថ្ងៃពុធ ៦រោជ ខែភទ្របទ ព.ស.២៥៤២ គ.ស. ១៩៩៨។ សាមណេរ ចាប ចារមិនបានស្អាតទេ ព្រោះទើបរៀនចារទេ។ បើសិនតែខុសអក្ខរាត្រង់ណាសូមជួយកែថែកខ្ញុំព្រះករុណាផង ។ សាមណេរ ចាប នៅភូមិគោកស្នួល បានចារច្បាប់ក្មេងមួយខ្សែទុកសម្រាប់វត្តខ្នារ។